# សន្និបាត
# បូកសរុបលទ្ធផលការងាររយៈពេល២ឆ្នាំកន្លះ
# (ខែកញ្ញា ឆ្នាំ២០១៣-ខែមីនា ឆ្នាំ២០១៦)

# និងលើកទិសដៅការងារឆ្នាំ២០១៦
# របស់ក្រសួងមុខងារសាធារណៈ
# រាជធានីភ្នំពេញ ថ្ងៃទី០៥-០៦ ខែមេសា ឆ្នាំ២០១៦

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារ និងបញ្ហាប្រឈមនៃការអនុវត្ត ការងារត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល

ឧទ្ទេសនាមដោយៈ ឯកឧត្តម ប៉ុល ពីឌូ រដ្ឋលេខាធិការ

# មាតិកា

១- សាវតារ

២- សមាសភាពក្រុមការងារ

៣- សកម្មភាព និងលទ្ធផលការងារ

៤- បញ្ហាប្រឈម

៥- ចំណុចខ្លាំង និង ចំណុចខ្សោយ

៦- សំណូមពរ

៧- សន្និដ្ឋាន

# ១-ឯកសារ

១- សេចក្តីណែនាំលេខ ០១ សណន. ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាល ស្តីពី តួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្មតាមមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល។

២- សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល។

# ១-សាវតារ (ត)

## ខ្លឹមសារសំខាន់ៗនៃសេចក្ដីណែនាំលេខ ០១ សណន

- អំពីតួនាទី និងភារកិច្ច របស់ក្រុមការងារចុះបំពេញបេសកកម្មតាមមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល៖

ក្នុងការបំពេញបេសកកម្មនៅមូលដ្ឋាន ក្រុមការងារមានតួនាទីលើកកម្ពស់កិច្ចសហការ សម្របសម្រួលក្នុងការដោះស្រាយបញ្ហានានា ដើម្បីបំរើផលប្រយោជន៍ជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។ ក្រុមការងារពុំមានតួនាទី ឬសិទ្ធិសម្រេចកិច្ចការជំនួសក្រសួង ស្ថាប័ននានាឡើយ។ រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ននីមួយៗនៅតែមានតួនាទី និងការទទួលខុសត្រូវស្របតាមគោលការណ៍ច្បាប់ដដែល។ ទន្ទឹមនេះ ក្រុមការងារក៏ពុំមានតួនាទីចាត់ចែងកិច្ចការជំនួសរដ្ឋបាលថ្នាក់ក្រោមជាតិ និងអាជ្ញាធរមានសមត្ថកិច្ចនានាឡើយ។ ក្រុមការងារមានភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

# ១-សាចតារ (ត)

១- ផ្សារភ្ជាប់ទំនាក់ទំនងរវាងរាជរដ្ឋាភិបាល ជាមួយប្រជាពលរដ្ឋ តាមរយៈការផ្សព្វផ្សាយអោយបានទូលំទូលាយនូវកម្មវិធីនយោបាយ យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ គោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព កម្មវិធីគោលនយោបាយតាមវិស័យ ក៏ដូចជាសភាពការណ៍រួមរបស់ប្រទេសជាតិ ដោយផ្សារភ្ជាប់ជាមួយសភាពការណ៍នៅមូលដ្ឋាន។

២- លើកកម្ពស់ការទទួលខុសត្រូវរបស់ក្រសួងស្ថាប័ន ក៏ដូចជារដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការត្រួតពិនិត្យ តាមដាន និងគាំទ្រការអនុវត្តកម្មវិធី គម្រោង និងផែនការសកម្មភាពនានានៅតាមមូលដ្ឋាន។

៣- សហការជំរុញ និងលើកកម្ពស់គណនេយ្យភាពរបស់ក្រសួង ស្ថាប័ន និង អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍន៍នៅមូលដ្ឋានអោយមានប្រសិទ្ធភាព។

# ១-សាចតារ (ត)

៤- សហការរៀបចំវេទិកាសាធារណៈនៅតាមមូលដ្ឋាន ដើម្បីស្តាប់សំណូមពរ និងសំណើរបស់ប្រជាពលរដ្ឋ ព្រមទាំងយកចិត្តទុកដាក់ដោះស្រាយនូវរាល់សំណូមពរ និងសំណើទាំងនោះដោយផ្អែកលើច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។ ក្នុងករណីមិនអាចដោះស្រាយបាន ក្រុមការងារត្រូវបូកសរុប និងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល។ វេទិកាសាធារណៈនេះគប្បីយកចិត្តទុកដាក់អំពីស្ថានភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

៥- សហការដោះស្រាយបញ្ហាប្រឈម និងការលំបាកនានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

៦- កៀគរធនធានពីប្រភពនានា ដើម្បីចូលរួមដោះស្រាយជីវភាពប្រជាពលរដ្ឋក៏ដូចជាការអភិវឌ្ឍមូលដ្ឋាន។

# ២- សមាសភាពក្រុមការងារ

ថ្នាក់ដឹកនាំ និងមន្រ្តីជំនាញដែលមានតួនាទីចាប់ពីអគ្គនាយករង ដល់រដ្ឋមន្រ្តីនៃក្រសួងមុខងារសាធារណៈ ដែលត្រូវចុះបំពេញបេសកកម្មតាមមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា មានចំនួនសរុប ៣០នាក់ ក្នុងនោះស្រ្តី ចំនួន ០៥នាក់។ ចំពោះគោលដៅនៃការចុះបំពេញបេសកកម្មនៅតាមមូលដ្ឋាន មានដូចជា៖

១- ឯកឧត្តម ពេជ្រ ប៊ុនធិន រដ្ឋមន្រ្តីក្រសួងមុខងារសាធារណៈ បំពេញបេសកកម្មជាអនុប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តក្រចេះ និងទទួលបន្ទុកជាប្រធានក្រុមការងារថ្នាក់ជាតិប្រចាំស្រុកស្នួល ខេត្តក្រចេះ

២- ឯកឧត្តម យូ ស៊ុនឡុង រដ្ឋមន្រ្តីប្រតិភូអមនាយករដ្ឋមន្រ្តី និងជារដ្ឋលេខាធិការ ចុះមូលដ្ឋាននៅស្រុកកងមាស ខេត្តកំពង់ចាម

៣- ឯកឧត្តម អៀម សារុំ រដ្ឋលេខាធិការ ចុះមូលដ្ឋាននៅខេត្តកំពង់ចាម

៤- ឯកឧត្តម រស់ សុផាន់ រដ្ឋលេខាធិការ ចុះមូលដ្ឋាននៅខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ

# ២- សមាសភាពក្រុមការងារ ( ត )

៥- លោកជំទាវ វ៉ាន់ ម៉ារ៉ា រដ្ឋលេខាធិការ ចុះមូលដ្ឋាននៅខេត្តសៀមរាប

៦- ឯកឧត្តម យក់ ប៊ុនណា  រដ្ឋលេខាធិការ ចុះមូលដ្ឋាននៅខេត្តព្រៃវែង

៧- ខ្ញុំបាទ ប៉ូល ពីខូ  រដ្ឋលេខាធិការ ចុះមូលដ្ឋាននៅខេត្តពោធិ៍សាត់

៨- ឯកឧត្តម ជុក មុន្នី  អនុរដ្ឋលេខាធិការ ចុះមូលដ្ឋាននៅខេត្តស្វាយរៀង

៩- ឯកឧត្តម ថោ សេដ្ឋាណា  អនុរដ្ឋលេខាធិការ ចុះមូលដ្ឋាននៅខេត្តបាត់ដំបង

១០-ឯកឧត្តម ខៀវ ច័ន្ទប៊ុនធឿន អនុរដ្ឋលេខាធិការ ចុះមូលដ្ឋាននៅខេត្តកំពង់ឆ្នាំង

១១-ឯកឧត្តម ឈឿន ប៊ុនណារ័ត្ន អនុរដ្ឋលេខាធិការ ចុះមូលដ្ឋាននៅខេត្តកណ្ដាល

១២-លោកជំទាវ សៅ សុគន្ធារី  អនុរដ្ឋលេខាធិការ ចុះមូលដ្ឋាននៅខេត្តមណ្ឌលគីរី

១៣-លោកជំទាវ ឈី វិដ្ឋូរ៉ា  អនុរដ្ឋលេខាធិការ ចុះមូលដ្ឋាននៅខេត្តកំពង់ស្ពឺ

១៤-ឯកឧត្តម សុខ វិសាល  អនុរដ្ឋលេខាធិការ ចុះមូលដ្ឋានខេត្តរតនៈគិរី

១៥-ឯកឧត្តម ហង្ស ឆាំឆាន  អនុរដ្ឋលេខាធិការ ចុះមូលដ្ឋាននៅខេត្តព្រៃវែង

# ២- សមាសភាពក្រុមការងារ ( ត )

១៦- ឯកឧត្តម ទិន  សុខឃួន  អនុរដ្ឋលេខាធិការ ចុះមូលដ្ឋាននៅខេត្តកោះកុង

១៧- ឯកឧត្តម ប្រាក់ វីក្រា អនុរដ្ឋលេខាធិការចុះមូលដ្ឋាននៅស្រុកស្នួលខេត្តក្រចេះ

១៨- ឯកឧត្តម ឆាយ ឆត្រាវុធ  អគ្គលេខាធិការរង ចុះមូលដ្ឋាននៅខេត្តកំពង់ធំ

១៩- លោកជំទាវ នាង លីណា  អគ្គលេខាធិការរង ចុះមូលដ្ឋាននៅខេត្តតាកែវ

២០- ឯកឧត្តម បាន់ វណ្ណី  អគ្គាធិការ ចុះមូលដ្ឋាននៅខេត្តព្រះវិហារ

២១- ឯកឧត្តម គង់ សុភី  អគ្គនាយក ចុះមូលដ្ឋាននៅស្រុកស្នួល ខេត្តក្រចេះ

២២- លោក អ៊ុល រ៉ូ  អគ្គនាយក ចុះមូលដ្ឋាននៅខេត្តកំពត

២៣- ឯកឧត្តម សរ សាម៉ុឌី  ទីប្រឹក្សាក្រសួង ចុះមូលដ្ឋាននៅខេត្តត្បូងឃ្មុំ

# ២- សមាសភាពក្រុមការងារ (ត)

២៤- ឯកឧត្តម សួន រ៉ានី នាយករងសាលាភូមិន្ទរដ្ឋបាល ចុះមូលដ្ឋាននៅខេត្ត ស្ទឹងត្រែង

២៥- លោក អ៊ុយ ភារក្ស អគ្គនាយករង ចុះមូលដ្ឋាននៅស្រុកស្នួល ខេត្តក្រចេះ

២៦- លោក នូ សុវណ្ណា  អគ្គនាយករង ចុះមូលដ្ឋាននៅខេត្តកែប

២៧- លោក ស៊ិម សារឿន  អគ្គនាយករង ចុះមូលដ្ឋាននៅខេត្តឧត្តរមានជ័យ

២៨-លោក ឈុន សុជាតិ  អគ្គនាយករង ចុះមូលដ្ឋាននៅខេត្តបន្ទាយមានជ័យ

២៩- លោកស្រី ឆាយ គីមសុទ្ធី  អគ្គនាយករង ចុះមូលដ្ឋាននៅខេត្តប៉ៃលិន

៣០- លោក មាស ពេជ្រ  អគ្គនាយករង ចុះមូលដ្ឋាននៅខេត្តព្រះសីហនុ

# ៣- សក្ខីភាព និងលទ្ធផលការងារ

- ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃក្រសួងមុខងារសាធារណៈបានចុះបំពេញបេសកកម្មយ៉ាងសកម្ម និងជាប្រចាំនៅតាមរាជធានី ខេត្ត តាមការចាត់តាំងរបស់រាជរដ្ឋាភិបាល។

- គ្រប់វេទិកាសាធារណៈដែលថ្នាក់ដឹកនាំ និងមន្ត្រីជំនាញរបស់ក្រសួងមុខងារសាធារណៈបានធ្វើឡើងនៅតាមគោលដៅនីមួយៗមានការចូលរួមដោយស្ម័គ្រចិត្តពីសំណាក់ប្រជាពលរដ្ឋទូទៅ និងមន្ត្រីរាជការគ្រប់ប្រភេទ ដោយមិនប្រកាន់និន្នាការនយោបាយ សាសនា ឬវណ្ណៈក្នុងសង្គមឡើយ ព្រមទាំងបានទទួលសំណួរ និងសំណូមពរពីអ្នកចូលរួមវេទិកានេះយ៉ាងច្រើនពាក់ព័ន្ធនឹងបញ្ហាសង្គម និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដូចជា ទំនាស់ដីធ្លី ប្លង់កម្មសិទ្ធិដីធ្លី ការបម្រើសេវាសាធារណៈ បទល្មើសព្រៃឈើ បទល្មើសបរិស្ថាន បទល្មើសនេសាទ បញ្ហាឡូដ៍នេសាទសហគមន៍ សេវាកម្មទឹកស្អាត អាជីវកម្មបូមខ្សាច់ អាជីវកម្មដឹកខ្សាច់ អាជីវកម្មកំពង់ដរ អាជីវកម្មសត្តឃាត តម្លៃទំនិញកសិផល ទីផ្សារកសិផល សណ្តាប់ធ្នាប់និងសន្តិសុខ សុវត្ថិភាពសាធារណៈ ការខ្វះការងារធ្វើ ការចំណាកស្រុករបស់ប្រជាពលរដ្ឋ ការដំឡើងប្រាក់ខែកម្មកររោងចក្រ ការធ្វើលិខិតឆ្លងដែន បទល្មើសចោរកម្ម បទល្មើសគ្រឿងញៀន ជីសង្គមកិច្ច បណ្តាញអគ្គិសនី និងតម្លៃអគ្គិសនី ការបាក់ច្រាំងទន្លេ ជនអន្តោប្រវេសន៍ខុសច្បាប់ បញ្ហាតុលាការ និងការសិក្សាខ្សោយរបស់សិស្ស ជាដើម។

# ៣-សកម្មភាពនិងលទ្ធផលការងារ (ត)

ដោយឡែក ចំពោះសំណួរ ឬសំណូមពរដែលបានលើកឡើងក្នុងវេទិកាសាធារណៈ ពាក់ព័ន្ធទៅនឹងវិស័យសាធារណៈ ឬមុខងារសាធារណៈ មានដូចជា៖ ប្រាក់បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ឬប្រាក់ឧបត្ថម្ភផ្សេងៗរបស់មន្ត្រី ប្រាក់ឧបត្ថម្ភសហព័ទ្ធ និងកូនក្នុងបន្ទុក គម្លាតគ្នារវាងប្រាក់សោធននិវត្តន៍របស់និវត្តន៍ជនជាអតីតមន្ត្រីរាជការស៊ីវិល ឬអតីតកងកម្លាំងប្រដាប់អាវុធ ការបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារដែលជួបការលំបាក ដោយសារមានទីតាំងនៅឆ្ងាយពីមូលដ្ឋានរស់នៅរបស់មន្ត្រីរាជការ ភាពខុសគ្នារវាងសោធននិវត្តន៍របស់និវត្តន៍ជនដែលមានក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ដូចគ្នា តែកាលបរិច្ឆេទនៃការចូលនិវត្តន៍ខុសគ្នា ការឡើងថ្នាក់ និងឋានន្តរស័ក្តិរបស់មន្ត្រីរាជការមានភាពខុសគ្នា ប្រាក់បៀវត្សមន្ត្រីរាជការនៅមានកម្រិត ការកាត់ពន្ធលើប្រាក់បៀវត្សរបស់មន្ត្រីរាជការ ការដំឡើងប្រាក់ឧបត្ថម្ភដល់គ្រូបង្រៀនជាប់កិច្ចសន្យា ការខ្វះគ្រូបង្រៀននៅកម្រិតអនុវិទ្យាល័យ វិទ្យាល័យនៅតាមមូលដ្ឋាន មន្ត្រីអប់រំមួយចំនួននៅមូលដ្ឋានមិនទាន់ទទួលបានការតែងតាំងក្នុងមុខតំណែងតាមរចនាសម្ព័ន្ធដែលមានស្រាប់ សិទ្ធិអំណាចមន្ត្រីស្មៀនឃុំនៅតាមមូលដ្ឋាន ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងការកំណត់តម្លៃសេវាអគ្រានុកូលដ្ឋាន។

# ៣-សកម្មភាពនិងលទ្ធផលការងារ (ត)

តាមរយៈវេទិកាសាធារណៈ ប្រជាពលរដ្ឋក៏ដូចជាមន្ត្រីរាជការបានលើកឡើងជាសំណូមពរ និងស្នើសុំអោយមានការជួយអភិវឌ្ឍន៍នៅតាមមូលដ្ឋាននានា ដូចជា៖ ការកសាងថ្មី និងការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជាសាលារៀន មណ្ឌលសុខភាព វត្តអារាម ផ្លូវលំជនបទ ផ្លូវជាតិ ស្ពាន ស្រះទឹក អណ្តូងទឹក លូទឹក ប្រឡាយទឹក ទំនប់ទឹក បង្គន់អនាម័យ បណ្តាញអគ្គិសនី បណ្តាញទឹកស្អាត។

សំណួរ ឬសំណូមពរដែលបានលើកឡើង ក្រុមការងារចុះមូលដ្ឋានដែលមានសមាសភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានធ្វើការឆ្លើយបំភ្លឺ ពន្យល់ និងបកស្រាយជូនប្រជាពលរដ្ឋ និងមន្ត្រីរាជការដែលបានចូលរួម ទាំងលើទិដ្ឋភាពច្បាប់ នយោបាយ បច្ចេកទេស និងជំនាញ ព្រមទាំងបានដោះស្រាយនូវសំណូមពររបស់ប្រជាពលរដ្ឋបានច្រើនគួរអោយកត់សម្គាល់។

ចំពោះសំណួរ ឬសំណូមពរដែលនៅសេសសល់ ក្រុមការងារកំពុងព្យាយាមសហការសម្របសម្រួល និងបន្តដោះស្រាយក្នុងក្របខណ្ឌសមត្ថកិច្ចរបស់អាជ្ញាធរមូលដ្ឋានភូមិ ឃុំ សង្កាត់ គណៈបញ្ជាការឯកភាព ក្រុង ស្រុក ខណ្ឌ គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុមការងារថ្នាក់ខេត្ត និងក្រុមការងារថ្នាក់ជាតិ ឬស្នើសុំគោលការណ៍ទៅរាជរដ្ឋាភិបាលតាមរយៈប្រធានក្រុមការងារថ្នាក់ជាតិប្រចាំរាជធានី ខេត្ត។

# ៤- បញ្ហាប្រឈម

ទោះបីជាក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានបានសកម្ម និងទទួលលទ្ធផលគួរឲ្យកត់សម្គាល់ក្តី ក៏ប៉ុន្តែនៅមានបញ្ហាប្រឈមខ្លះៗដែលជាក្រុមការងារបាន និងកំពុងជួបប្រទះដូចជា៖

១- កម្មវិធីការងាររបស់ក្រុមការងារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មមាញឹកច្រើនពេកជាហេតុនាំអោយមានការពិបាកក្នុងការចុះធ្វើវេទិការសាធារណៈព្រោះក្រុមការងារមិនបានចូលរួមជុំគ្នាគ្រប់សមត្ថកិច្ចជំនាញ។

២- មធ្យោបាយសម្រាប់គាំទ្រដល់ការចុះបំពេញការងារនៅមានកម្រិត ។

៣-សំណួរ ឬសំណូមពរពីប្រជាពលរដ្ឋ និងមន្ត្រីរាជការមួយចំនួនមិនទាន់បានដោះស្រាយចប់

៤- កាផ្តល់សេវាសាធារណៈពាក់ព័ន្ធទៅនឹងការផ្តល់កម្មសិទ្ធិលំនៅស្ថាន កម្មសិទ្ធិដីធ្លី ការផ្តល់អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ សំបុត្រកំណើត នៅមានការយឺតយ៉ាវ

# ៤- បញ្ហាប្រឈម ( ត )

៥- ធនធានមនុស្សនៃមន្ត្រីជំនាញនៅក្នុងក្រុមការងារនៅមានកម្រិត
៦- បទល្មើសគ្រប់ប្រភេទនៅមានច្រើននៅតាមមូលដ្ឋាន
៧- រាល់ពេលចុះបំពេញការងារមូលដ្ឋានរបស់ក្រុមការងារថ្នាក់ជាតិ សមាជិកក្រុមការងារទាំងអស់តែងតែប្រមូលថវិកាផ្ទាល់ខ្លួនដើម្បីចំណាយលើការរៀបចំវេទិកាសាធារណៈ
៨-ការធ្វើវេទិកាសាធារណៈនៅកន្លែងខ្លះ ពេលខ្លះ ពុំដែលមានការចូលរួមពីមន្ទីរ ឬមន្ត្រីមន្ត្រីជំនាញថ្នាក់រាជធានី ខេត្តទេ ដែលបញ្ហានេះមានការលំបាកក្នុងការដោះស្រាយ និងត្រូវអូសបន្លាយពេលវេលា។

# ៥- ចំណុចខ្លាំង និងចំណុចខ្សោយ

## ចំណុចខ្លាំង

- ប្រជាពលរដ្ឋកាន់តែបានយល់ដឹងអំពីកម្មវិធីនយោបាយ និងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ក៏ដូចជាការងារអភិវឌ្ឍន៍មានការរីកចម្រើនលើគ្រប់វិស័យ និងឆ្លើយតបកាន់តែប្រសើរឡើងចំពោះតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។
- ការផ្តល់សេវាសាធារណៈមានភាពកាន់តែប្រសើរឡើង មានទំនុកចិត្តពីប្រជាពលរដ្ឋ ដោយមានការបិទផ្សាយជាសាធារណៈនូវតារាងតម្លៃសេវា ធ្វើអោយមានតម្លាភាព និងទប់ស្កាត់បាននូវបញ្ហាអសកម្ម។
- ក្រុមការងារថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត និងអាជ្ញាធរមូលដ្ឋាន បានសហការគ្នាអនុវត្តបានល្អ ទាំងការងារចុះរៀបចំវេទិកា ការពន្យល់ ការបកស្រាយ បំភ្លឺ ក៏ដូចជាការប្រជុំបូកសរុបដកពិសោធន៍ និងការប្រជុំដោះស្រាយកង្វល់ និងសំណូមពររបស់ប្រជាពលរដ្ឋ។
- ការរៀបចំវេទិកាសាធារណៈ បានធ្វើអោយប្រជាពលរដ្ឋមានឱកាសលើកឡើងនូវបញ្ហាដែលជាទុក្ខកង្វល់ពិតប្រាកដរបស់ពួកគាត់។

**ចំណុចខ្សោយ**

- ខ្វះមធ្យោបាយសម្រាប់ចុះបំពេញបេសកកម្ម
- ខ្វះថវិកាសម្រាប់រៀបចំវេទិកាសាធារណៈ
- ការបកស្រាយបំភ្លឺរបស់ស្ថាប័នជំនាញពាក់ព័ន្ធមួយចំនួននៅមិនទាន់ឆ្លើយតបច្បាស់លាស់ទៅនឹងសំណួរ និងសំណូមពររបស់ប្រជាពលរដ្ឋ
- សំណូមពរមួយចំនួនរបស់ប្រជាពលរដ្ឋមានទំហំធំ ហួសសមត្ថកិច្ចរបស់ក្រុមការងារ
- សំណូមពររបស់ប្រជាពលរដ្ឋដែលបានបញ្ជូនទៅជំនាញពាក់ព័ន្ធ ដោះស្រាយបានមួយចំនួន នៅសេសសល់មួយចំនួនទៀត រង់ចាំជំនាញពាក់ព័ន្ធដោះស្រាយបន្ត
- ការផ្សព្វផ្សាយពីគោលបំណងរបស់វេទិកា មិនទាន់បានទូលំទូលាយ នៅមុនពេលប្រជាជនចូលរួម។

# ៦- សំណូមពរ

- ស្នើសុំអោយមានមធ្យោបាយ និងកញ្ចប់ថវិការផ្គត់ផ្គង់សម្រាប់រៀបចំវេទិកាសាធារណៈ និងកិច្ចប្រជុំផ្សេងៗរបស់ក្រុមការងារ
- ស្នើអោយសមាជិកក្រុមការងារថ្នាក់រាជធានី ខេត្ត មន្ទីរជំនាញ និងអាជ្ញាធរមូលដ្ឋានចូលរួមគ្រប់វេទិកាសាធារណៈ
- ស្នើអោយមានយន្តការដោះស្រាយសំណូមពររបស់ប្រជាពលរដ្ឋមានភាពច្បាស់លាស់ ចៀសវាងទទួលសំណូមពរហើយពុំមានការដោះស្រាយ
- សូមអោយមានការផ្សព្វផ្សាយពីគោលបំណងរបស់វេទិកាសាធារណៈបានទូលំទូលាយ នៅមុនពេលធ្វើវេទិកាម្តងៗ
- ពេលរៀបចំកម្មវិធីវេទិកាសាធារណៈនីមួយៗ ក្រុមការងារថ្នាក់ជាតិ ដែលចុះតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវជូនព័ត៌មានជាមុនដល់អាជ្ញាធររាជធានី ខេត្ត និងក្រុមជំនួយការរបស់ក្រុមការងារថ្នាក់ជាតិ។

# ៧- សន្និដ្ឋាន

ជាទូទៅយើងសង្កេតឃើញថា ដំណើរការគ្រប់វេទិកាសាធារណៈបានប្រព្រឹត្តទៅដោយរលូន មានលក្ខណៈសមរម្យ និងមានការចូលរួមពីប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ និងនិន្នាការនយោបាយ ។

អង្គវេទិកាធ្វើឡើងដោយបើកចំហ ហើយប្រជាជនបានបង្ហាញពីភាពក្លាហាន និងការចូលរួមរបស់ខ្លួនតាមរយៈការលើកឡើងនូវមតិយោបល់នានាក្នុងលក្ខណៈ ជាការរិះគន់ត្រង់ៗផង ជាសំណូមពរផង ជាការរិះគន់ក្នុងន័យស្ថាបនាផងព្រមទាំងការផ្តល់ព័ត៌មានត្រឡប់ជាក់ស្តែងផង។

ការផ្តល់ព័ត៌មានត្រឡប់ ឬការផ្តល់យោបល់របស់ប្រជាជនក្នុងវេទិកាសាធារណៈ ប្រៀបបានជាកញ្ចក់ឆ្លុះបញ្ចាំងនូវរាល់ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ព័ត៌មានទាំងនេះជារួម គឺជាព័ត៌មានល្អសម្រាប់មន្ត្រីគ្រប់លំដាប់ថ្នាក់ ក្នុងការកែលម្អខ្លួនអោយបានសមស្របតាមអនុសាសន៍ណែនាំរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** គឺ **“ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់”**

# ៧- សន្និដ្ឋាន

មតិ យោបល់ ឬ សំនួរដែលមានលក្ខណៈជាសំណូមពរស្របទៅនឹង ជីវភាពជាក់ស្តែងរបស់ប្រជាជន ត្រូវបានដោះស្រាយជូនប្រជាពលរដ្ឋ ធ្វើអោយប្រជាពលរដ្ឋមានការសប្បាយចិត្ត ដូចជាការងារពាក់ព័ន្ធនឹងការរក្សាសណ្តាប់ធ្នាប់សន្តិសុខសង្គម និងការអភិវឌ្ឍន៍ជនបទ ជាដើម។

តាមរយៈសកម្មភាព និងលទ្ធផលការងាររបស់ក្រុមការងារថ្នាក់ជាតិនៃក្រសួងមុខងារសាធារណៈ កន្លងមកនេះ យើងអាចវាយតម្លៃបានថា សកម្មភាពនេះជាយន្តការដ៏មានប្រសិទ្ធភាពមួយក្នុងការជួយដោះស្រាយនូវបញ្ហាសំណួរ និងសំណូមពររបស់ប្រជាពលរដ្ឋ និងមន្ត្រីរាជការនៅតាមមូលដ្ឋាន។

# ៧- សន្និដ្ឋាន( ត )

តាមរយៈសកម្មភាពចុះមូលដ្ឋាននេះផងដែរ ក្រុមការងារនៃក្រសួងមុខងារសាធារណៈបានធ្វើការបំភ្លឺ បកស្រាយ និងពន្យល់តបទៅនឹងការលើកឡើងរបស់ប្រជាពលរដ្ឋ និងមន្ត្រីរាជការនៅនឹងកន្លែងឲ្យអស់ពីលទ្ធភាព ហើយក្នុងករណីដែលបញ្ហានៅសេសសល់ ក្រុមការងារកំពុងព្យាយាមបន្តដោះស្រាយដោយសហការជាមួយនិងអាជ្ញាធរមូលដ្ឋាន ក្រុមការងារថ្នាក់ខេត្ត និងក្រុមការងារថ្នាក់ជាតិ ឬស្នើសុំគោលការណ៍ទៅរាជរដ្ឋាភិបាល តាមរយៈប្រធានក្រុមការងារថ្នាក់ជាតិប្រចាំរាជធានី ខេត្តនីមួយៗ តែយ៉ាងណាក្តី ក្រុមការងារក៏នៅជួបនូវបញ្ហាប្រឈមមួយចំនួនក្នុងការអនុវត្តសកម្មភាពការងារនេះ ដូចបានលើកឡើងខាងដើម។

# ៧- សន្និដ្ឋាន( ត )

ជារួម កិច្ចខិតខំប្រឹងប្រែង និងលទ្ធផលការងារដែលក្រុមការងារបានសម្រេចក្នុងការចុះបំពេញបេសកកម្មនៅតាមមូលដ្ឋានរយៈពេលជាងពីរឆ្នាំនេះ គឺបានរួមចំណែកក្នុងការថែរក្សាពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងជាពិសេសបានកំពុងជំរុញអនុវត្តយ៉ាងសកម្មនូវកម្មវិធីកំណែទម្រង់ពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ ឲ្យកាន់តែមានលក្ខណៈទូលំទូលាយនិងស៊ីជម្រៅថែមទៀត ដើម្បីប្រែក្លាយរដ្ឋបាលសាធារណៈឲ្យទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាពនិងជាដៃគូអភិវឌ្ឍន៍ដែលអាចជឿទុកចិត្តបាន សំដៅបម្រើប្រជាជនឲ្យបានកាន់តែល្អប្រសើរឡើង។

# សូមអរគុណ